ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១១០/១៦ - ញូ អាកឃីត ហ្វាមេន ហ្វេកធើរី លីមីតធីត

កាលបរិច្ឆេទនៃសេចក្តីសម្រេច៖ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦

# សេចក្តីសម្រេចអាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង វុចហ៊ិន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ញូ អាកឃីត ហ្វាមេន ហ្វេកធើរី លីមីតធីត**

អាសយដ្ឋាន ៖ ភូមិត្រពាំងភូមិ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១២ ៩៥០ ៤០៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- លោក អ៊ឹង ប៊ុនឡុង ប្រធានរដ្ឋបាល

២- លោក អឿន សំអុល រដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពកម្មករឧស្សាហកម្មកាត់ដេរកម្ពុជា**

- **សហព័ន្ធសហជីពសេរីភាពកម្មករខ្មែរ**

- **សហព័ន្ធសហជីពពលកម្មកម្ពុជា**

អាសយដ្ឋាន ៖ ភូមិសាមគ្គី៥ សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១១ ៧០០ ០១១/០១២ ៦៣៨ ៩៧៧ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖ អវត្តមាន



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤

No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824

E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើសុំឱ្យក្រុមហ៊ុនទទួលយកតំណាងកម្មករចំនួន ០៣ នាក់ លោក ចែម សម្ផស្ស អត្តលេខ ១០៦២៦៨, លោក វ៉ាយ វ៉ាន់នី អត្តលេខ ១១៩៣១៤ និងលោក អេង សុវណ្ណ អត្តលេខ ១១៩៤៥៣។

២- ស្នើសុំប្រាក់ធ្វើដំណើរចំនួន ១០ ដុល្លារអាមេរិក បន្ថែម ស្មើ ១៧ ដុល្លារអាមេរិក នៅក្នុងមួយខែ។

៣- ស្នើសុំប្រាក់ទ្រទ្រង់សុខភាពចំនួន ៨ ដុល្លារអាមេរិក ក្នុងមួយខែ។

៤- ស្នើសុំប្រាក់រង្វាន់ទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក បន្ថែម ស្មើ ២០ ដុល្លារអាមេរិក ក្នុងមួយខែ។

៥- ស្នើសុំប្រាក់ជំនាញតាមម៉ាស៊ីនចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ។

៦- ស្នើសុំប្រាក់ថ្លៃបាយចំនួន ២០០០ រៀល ក្នុងមួយម៉ោង ចំពោះកម្មករនិយោជិត ស្ម័គ្រចិត្តថែមម៉ោងចាប់ពីម៉ោង ១៦៖០០ ទៅដល់ម៉ោង ១៨៖០០។

៧- ស្នើសុំបើកប្រាក់បំណាច់ឆ្នាំចំនួន ២ ដង ក្នុងមួយឆ្នាំ (បុណ្យចូលឆ្នាំ និងបុណ្យភ្ជុំបិណ្ឌ)។

៨- ស្នើសុំប្រើប្រាស់ច្បាប់ពិសេស ដោយមិនត្រូវកាត់ប្រាក់ឈ្នួលការឈប់សម្រាកប្រចាំឆ្នាំ ហើយរក្សាអត្ថប្រយោជន៍ផ្សេងៗនៅដដែល។

៩- ស្នើសុំកាត់រង្វាន់ទៀងទាត់តាមសមាមាត្រចំពោះកម្មករនិយោជិតដែលបានសុំច្បាប់ ហើយឯកភាពពីក្រុមហ៊ុន។

១០- ស្នើក្រុមហ៊ុនធ្វើស្ពានឆ្លង សម្រាប់កម្មករនិយោជិតឱ្យបានត្រឹមត្រូវ។

១១- ស្នើក្រុមហ៊ុនធ្វើពីដប់លៀងជូនកម្មករនិយោជិត។

១២- ស្នើសុំឱ្យក្រុមហ៊ុនបញ្ឈប់ការកាត់លុយកម្មករមកយឺតក្រោម ១៥ នាទី។

១៣- ស្នើសុំក្រុមហ៊ុនកុំកាត់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗនៅពេលកម្មករនិយោជិតមានជម្ងឺហើយមានលិខិតបញ្ជាក់ត្រឹមត្រូវ។

១៤- ស្នើសុំកុំកាត់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗក្នុងកំឡុងពេលកូដកម្ម។

១៥- ស្នើសុំឱ្យក្រុមហ៊ុនទទួលយកកម្មករឈ្មោះ សន សោភា និង ផល ភ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញា កណ្តាលលេខ ៣២១ កប/ប្រក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ (អាណត្តិទី១៣)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីពីលទ្ធផលនៃការដោះស្រាយវិវាទរួម លេខ ៧០៨/១៦ កប/កណ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០១៦ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦។

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៦ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាល បានទទួលពាក្យបណ្ដឹងរបស់សហព័ន្ធសហជីពឧស្សាហកម្មកាត់ដេរកម្ពុជា សហព័ន្ធសហជីពសេរីភាពកម្មករខ្មែរ សហព័ន្ធសហជីពពលករកម្ពុជា និងសហព័ន្ធសហជីពមិត្តភាពកម្មករ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ ។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងនេះមក មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាល បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ និងបានធ្វើការផ្សះផ្សានៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ។ ចំណុចមិនសះជា ដែលនៅសល់ចំនួន ១៥ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ញូ អាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត លេខ ៧០៨/១៦ ក.ប/ក.ណ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើង នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១៦។ ដោយឡែក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទទួលព័ត៌មានថា បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល កម្មករនិយោជិតកំពុងធ្វើកូដកម្ម។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទទួលលិខិតមួយច្បាប់របស់ក្រុមហ៊ុន ញូ អាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីសំណើសុំក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចេញសេចក្ដីបញ្ជាដើម្បីផ្អាកការធ្វើកូដកម្ម ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជាលេខ ០០៨/១៦ កបអ. ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ញូ អាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត រហូតដល់នីតិវិធីនៃអាជ្ញាកណ្ដាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីរសៀលថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ តទៅ តាមវេនរបស់ខ្លួន។ ដោយឡែករហូតដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ លេខាធិការដ្ឋានបានទទួលព័ត៌មានថា កម្មករនិយោជិតបានចូលធ្វើការវិញអស់ហើយ ។ ហេតុនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១៥ ចំណុចនេះ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ភាគីនិយោជកមានវត្តមាននៅថ្ងៃសវនាការ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ ចំណែក សហព័ន្ធ

សហជីពឧស្សាហកម្មកាត់ដេរកម្ពុជា សហព័ន្ធសហជីពសេរីភាពកម្មករខ្មែរ សហព័ន្ធសហជីពពលករកម្ពុជា និង សហព័ន្ធសហជីពមិត្តភាពកម្មករ ទទួលបានការផ្ទេរសិទ្ធិពីកម្មករនិយោជិតនៃក្រុមហ៊ុន ញូ អាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត ចំនួន ០៥ នាក់ ក្នុងការដោះស្រាយនៅក្នុងសំណុំរឿងនេះ មិនមានវត្តមានក្នុងសវនាការទេ ។ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទាក់ទងតាមរយៈទូរស័ព្ទទៅសហព័ន្ធសហជីពទាំងបួន ដោយសហព័ន្ធសហជីពមិត្តភាពកម្មករបានបញ្ជាក់ថា សហព័ន្ធសហជីពមិត្តភាពកម្មករនេះដកខ្លួនចេញពីសំណុំរឿងនេះ ។ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១៦ សហព័ន្ធសហជីពទាំង០៤ ខាងលើនេះ មិនបានមកចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមការអញ្ជើញនោះទេ ដោយមន្ត្រីសហព័ន្ធខាងលើនេះបានបញ្ជាក់តាមរយៈទូរស័ព្ទនៅថ្ងៃសវនាការ ជាមួយមន្ត្រីលេខា ធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា សហព័ន្ធសហជីពបានដោះស្រាយសំណុំរឿងនេះជាមួយនិយោជកចប់ហើយ ដោយសហព័ន្ធសហជីពសម្រេចដកសំណុំរឿងនេះ ហើយពួកគាត់នឹងបញ្ជូនលិខិតដកសំណុំរឿងនៅពេលក្រោយ ។ យ៉ាងណាមិញ រហូតដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានទទួលលិខិតដកសំណុំរឿងរបស់សហព័ន្ធសហជីពទាំងបួននោះទេ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

- លិខិតចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន ញូ អាកឃីត ហ្គាមេន ហ្វេកធើរី លីមីធីត ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជាដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ញូ អាកឃីត ហ្គាមេន ហ្វេកធើរី លីមីធីត។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ញូ អាកឃីត ហ្គាមេន ហ្វេកធើរី លីមីធីត លេខ ៧០៨/១៦ កប/កណ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦។

២- កំណត់ហេតុស្តីពីការផ្សះផ្សាវិវាទការងាររួមនៅ ញូ អាកឃីត ហ្គាមេន ហ្វេកធើរី លីមីធីត ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតជ្រើសរើសអាជ្ញាកណ្តាល លេខ ៦០៦ កប/អក/វក/... ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦។

២- សេចក្តីបញ្ជារបស់អាជ្ញាកណ្តាលលេខ ០០៨/១៦ កបអ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ។

THE ARBITRATION COUNCIL

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៦៤៣ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៦៤៤ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ។

## អង្គហេតុ

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ ដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញា កណ្តាលទេ ដោយសារភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងមិនបានចូលរួមនីតិវិធីបន្តក្នុងសវនាការ ។

## ហេតុផលនៃសេចក្តីសម្រេច:

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរឬទេ ក្នុងករណីអវត្តមានរបស់ភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹង ?

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់ "* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់ ។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញា កណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"* ។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ីម និង វ៉េ ៣, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១១/១១-ជូន តិចថាយល៍, លេខ ១៣១/១២-ម៉ាស្ទ័រ & ប្រែហ្វង លេខ ១០៨/១៣-អាត់តូ និងលេខ ៣៣២/១៤-ធី &ខេ ហ្គាមេន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយ ប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាល *លក្ខខណ្ឌទី១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ, លក្ខខណ្ឌទី២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះ មុខក្រុមអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន"* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុង

សំណុំរឿងមុនៗខាងលើដែរ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ ?

**លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ**

លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីកម្មករនិយោជិត ដើម្បីឱ្យមកចូលរួមក្នុងសវនាការ អាជ្ញាកណ្តាលយ៉ាងត្រឹមត្រូវ តាមរយៈលិខិតអញ្ជើញលេខ ៦៤៤ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ដែលនៅក្នុងលិខិតនោះ បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការ គឺនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ ។ លើសពីនេះទៀត មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទាក់ទងតាមរយៈទូរស័ព្ទទៅសហព័ន្ធសហជីពកម្មករឧស្សាហកម្មកាត់ដេរកម្ពុជា សហព័ន្ធសហជីពសេរីភាពកម្មករខ្មែរ និងសហព័ន្ធសហជីពពលកម្មកម្ពុជា នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ចំណែកឯសហព័ន្ធសហជីពមិត្តភាពកម្មករ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ អំពីការអញ្ជើញគាត់ឱ្យមកចូលរួមសវនាការ ។ ដោយឡែក នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ សហព័ន្ធសហជីពទាំង០៤ ខាងលើនេះ មិនបានមកចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមការអញ្ជើញនោះទេ ដោយមន្ត្រីសហព័ន្ធសហជីពខាងលើនេះបានបញ្ជាក់តាមរយៈទូរស័ព្ទនៅថ្ងៃសវនាការ ជាមួយមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា សហព័ន្ធសហជីពបានដោះស្រាយសំណុំរឿងនេះជាមួយនិយោជកចប់ហើយ ដោយសហព័ន្ធសហជីពសម្រេចដកសំណុំរឿងនេះ ហើយពួកគាត់នឹងបញ្ជូនលិខិតដកសំណុំរឿងនៅពេលក្រោយ ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីដើមបណ្តឹងពិតជាទទួលបានការអញ្ជើញត្រឹមត្រូវពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន ។ ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ ។

**លក្ខខណ្ឌទី ២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "*ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល*" នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់ ។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ សហព័ន្ធសហជីពឧស្សាហកម្មកាត់ដេរកម្ពុជា សហព័ន្ធសហជីពសេរីភាពកម្មករខ្មែរ សហព័ន្ធសហជីពពលករកម្ពុជា និងសហព័ន្ធសហជីពមិត្តភាពកម្មករ មិនមានវត្តមាននៅក្នុងសវនាការទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីដើមបណ្តឹងមិនមានវត្តមាននៅក្នុងសវនាការ ហើយក៏មិនបានចូលរួមគ្រប់ដំណាក់កាលទាំង

THE ARBITRATION COUNCIL

បួនខាងលើនេះ ។ ហេតុនេះ ភាគីដើមបណ្តឹងមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល តាមខ្លឹមសារប្រការ ២១ នៃប្រកាសលេខ ០៩៩ លើនេះទេ ។ ដូចនេះ លក្ខខណ្ឌទី២ ត្រូវបានបំពេញ ។

**លក្ខខណ្ឌទី ៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

នៅថ្ងៃសវនាការ សហព័ន្ធសហជីពទាំងបួន ដែលជាតំណាងរបស់កម្មករនិយោជិតក្នុងសំណុំរឿងនេះ មិនមានវត្តមាននៅក្នុងសវនាការទេ ហើយថែមទាំងបានបញ្ជាក់តាមទូរស័ព្ទជាមួយមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា សហព័ន្ធសហជីពសម្រេចដកសំណុំរឿង នេះប៉ុន្តែនឹងបញ្ជូនលិខិតដកសំណុំរឿងនៅពេលក្រោយ ។ ដោយឡែករហូតដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ សហព័ន្ធសហជីពទាំងបួននេះ មិនបានមកដកសំណុំរឿងនេះទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការមិនមានវត្តមាននៅថ្ងៃសវនាការ ដោយបញ្ជាក់ថា នឹងធ្វើការដកសំណុំរឿង ប៉ុន្តែសហព័ន្ធសហជីពបែរជាមិនមកដកសំណុំរឿង គឺមិនអាចចាត់ទុកថាមានមូលហេតុត្រឹមត្រូវនោះទេ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ដើមបណ្តឹងមិនមានហេតុផលត្រឹមត្រូវ សម្រាប់ការមិនមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ដូច្នេះ លក្ខខណ្ឌទី៣ ត្រូវបានបំពេញ ។

សរុបសេចក្តីមក លក្ខខណ្ឌទាំងបីដែលមានចែងក្នុង ប្រការ២១ នៃប្រកាសលេខ ០៩៩ ខាងលើ ត្រូវបានបំពេញ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កាតព្វកិច្ចរបស់ភាគីដើមបណ្តឹង និងភាគីចុងបណ្តឹងនៃសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺត្រូវមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន ក៏ដូចជាផ្តល់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗដែលពាក់ព័ន្ធនឹងចំណុចវិវាទ សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចសេចក្តី ។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងទាមទាររបស់ខ្លួន ។ ចំណែកឯភាគីចុងបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះបន្ទុករបស់ខ្លួនពីការទាមទារពីសំណាក់ដើមបណ្តឹង ដែលកាតព្វកិច្ចនេះជាទូទៅ នឹងត្រូវកើតឡើងក្រោយពេលដែលដើមបណ្តឹងបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាមុនសិន ។

ក្នុងសំណុំរឿងនេះ ភាគីដើមបណ្តឹងមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបំពេញនូវកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ ។ លើសពីនេះ ភាគីដើមបណ្តឹងក៏មិនមានមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះដែរ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ភាគីដើមបណ្តឹងបានបោះបង់ចោលការទាមទាររបស់ខ្លួនហើយ ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនចាំបាច់បន្តដំណើរការអាជ្ញាកណ្តាលនោះទេ ។

ហេតុនេះ ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា

THE ARBITRATION COUNCIL

ដើមបណ្ដឹងបានបោះបង់ចោលពាក្យបណ្ដឹងរបស់ខ្លួន ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយចេញសេចក្ដីបង្គាប់ ។

ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងលេខ ១១០/១៦-ក្រុមហ៊ុន ញូ អាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត នេះ ។

យោងតាមអង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច ដូចតទៅ ៖

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្ដាលនៃសំណុំរឿងលេខ ១១០/១៦-ក្រុមហ៊ុន ញូ អាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **សេខ ទូចហ៊ុន**

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ឡូន ស៊ីផាន់**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា: ------------------------------------